ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលក្រមរដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណីលេខ៣៥

ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០

សាលក្រមរដ្ឋប្បវេណីលេខ១៥

ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១

# សាលក្រមរដ្ឋប្បវេណី

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តមណ្ឌលគិរី

**ចៅក្រម**

លោក [redacted] ជាចៅក្រមនៃសាលាដំបូងខេត្តមណ្ឌលគិរី

**ក្រឡាបញ្ជី**

លោកស្រី [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តមណ្ឌលគិរី

**រវាងដើមចោទ៖** ឈ្មោះ [redacted] សុភា ភេទស្រី អាយុ៣២ ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន[redacted]។

**និងចុងចម្លើយ៖** ឈ្មោះ [redacted] ផុន្នី ភេទប្រុស អាយុ៣៨ ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន[redacted]។

អ្នកតំណាងដោយអាណត្តិលោកស្រី [redacted] អត្តលេខ២០៥៧T មានអាសយដ្ឋាន[redacted]។

## អង្គហេតុនិងចំណុចវិវាទ

**ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ**

១.សុំលែងលះពីប្តីឈ្មោះ [redacted] ផុន្នី ភេទប្រុស អាយុ៣៨ ឆ្នាំ សញ្ជាតិខ្មែរ។

២.សុំឲ្យតុលាការសម្រេចអំពីសិទ្ធិអំណាចមេបា លើកូនឈ្មោះ [redacted] អ៊ីហ្វី ភេទស្រី អាយុ១១ឆ្នាំ និងឈ្មោះ [redacted] គីរីរម្យ ភេទប្រុស អាយុ០៦ឆ្នាំ។

៣.ទ្រព្យសម្បត្តិរួមជាអចលនវត្ថុចំនួន០៣ កន្លែងមាន៖ ដីទំហំ៣៣៩ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ១១០៤០២០២-០០៧២ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៣ ស្ថិតនៅភូមិពូជ្រៃចាង ឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ,ដីទំហំ១១៧៥២ ម៉ែត្រការ៉េ ដែលមានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ១០០២/១៦ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៦ ស្ថិតនៅភូមិពូជ្រៃចាង ឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី និងដីទំហំ៧២០០ ម៉ែត្រការ៉េ ដែលមានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ១០០៣/១៦ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៦ ស្ថិតនៅ/



Scanned with CamScanner

ភូមិពូជ្រៃចាង ឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ប្រគល់ឱ្យទៅកូនឈ្មោះ [redacted] អ៊ីហ្វី ភេទស្រី អាយុ១១ឆ្នាំ និងឈ្មោះ [redacted] គិរីរម្យ ភេទប្រុស អាយុ៦ឆ្នាំ។

៤.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

**១.ការពន្យល់ត្រួសៗអំពីរឿងក្តី (អង្គហេតុ)**

ដើមចោទបានរៀបអាពាហ៍ពិពាហ៍នៅអំឡុងឆ្នាំ២០០៦ ជាមួយចុងចម្លើយឈ្មោះ [redacted] ផុន្នី ប៉ុន្តែពុំមានចុះសំបុត្រអាពាហ៍ពិពាហ៍នោះទេ និងបានរួមរស់ជាមួយគ្នា រហូតដល់បច្ចុប្បន្នមានកូនចំនួន០២ នាក់ មានឈ្មោះ [redacted] អ៊ីហ្វី ភេទស្រី អាយុ១១ឆ្នាំ និងឈ្មោះ [redacted] គីរីរម្យ ភេទប្រុស អាយុ០៦ឆ្នាំ ព្រមទាំងមានទ្រព្យសម្បត្តិរួម៖ ដីទំហំ៣៣៩ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ១១០៤០២០២-០០៧២ ស្ថិតនៅភូមិពូជ្រៃចាង ឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ,ដីទំហំ១១៧៥២ ម៉ែត្រការ៉េ ដែលមានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ១០០២/១៦ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៦ ស្ថិតនៅភូមិពូជ្រៃចាង ឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី និងដីទំហំ៧២០០ ម៉ែត្រការ៉េ ដែលមានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ១០០៣/១៦ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៦ ស្ថិតនៅភូមិពូជ្រៃចាង ឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី។ មូលហេតុដែលដើមចោទសុំលែងលះ ដោយហេតុថា ដើមចោទរស់នៅជាមួយចុងចម្លើយឈ្មោះ [redacted] ផុន្នី មិនមានភាពចុះសម្រុងនឹងគ្នា ហើយចុងចម្លើយមិនមានភាពស្មោះត្រង់ និងលួចលាក់មានស្រីថ្មី។ ជាហេតុធ្វើឱ្យដើមចោទសុំឱ្យតុលាការចេញសាលក្រម តាមការទាមទារខាងលើ។

**២. អង្គហេតុដែលអះអាងដោយភាគី**

**២.១ ដើមចោទឈ្មោះ [redacted] សុភា ថ្លែងការណ៍ថា៖**

ខ្លួនសុំលែងលះពីប្តីឈ្មោះ [redacted] ផុន្នី ចំណែកទ្រព្យសម្បត្តិរួមមាន៖ ដីទំហំ៣៣៩ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ១១០៤០២០២-០០៧២ ស្ថិតនៅភូមិពូជ្រៃចាង ឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ,ដីទំហំ១១៧៥២ ម៉ែត្រការ៉េ ដែលមានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ១០០២/១៦ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៦ ស្ថិតនៅភូមិពូជ្រៃចាង ឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី និងដីទំហំ៧២០០ ម៉ែត្រការ៉េ ដែលមានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ១០០៣/១៦ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៦ ស្ថិតនៅភូមិពូជ្រៃចាង ឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ខ្លួនសុំប្រគល់ទៅឱ្យកូនឈ្មោះ [redacted] អ៊ីហ្វី ភេទស្រី អាយុ១១ឆ្នាំ និងឈ្មោះ [redacted] គិរីរម្យ ភេទប្រុស អាយុ៦ឆ្នាំ។ បច្ចុប្បន្នទ្រព្យសម្បត្តិរួមខាងលើ ខ្លួនសុំឱ្យចុងចម្លើយជាអ្នកថែរក្សាជាបណ្តោះអាសន្ន រហូតកូនដល់វ័យនីតិភាព។ ចំពោះសិទ្ធិគ្រប់គ្រងអំណាចមេបាលើកូនឈ្មោះ [redacted] អ៊ីហ្វី ភេទស្រី អាយុ១១ឆ្នាំ និងឈ្មោះ [redacted] គិរីរម្យ ភេទប្រុស អាយុ៦ឆ្នាំ ខ្លួនស្របតាមការការសម្រេចចិត្តរបស់កូនទាំងពីរ ដែលសុខចិត្តរស់នៅជាមួយឪពុក។

២.២ ចុងចម្លើយឈ្មោះ [redacted] ផុន្នី ថ្លែងការណ៍តបថា៖ ចំពោះទ្រព្យសម្បត្តិរួមមាន៖ ដីទំហំ៣៣៩ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ១១០៤០២០២-០០៧២ ស្ថិតនៅភូមិពូជ្រៃចាង ឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ,ដីទំហំ១១៧៥២ ម៉ែត្រការ៉េ ដែលមានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ១០០២/១៦ ចុះថ្ងៃទី២៩.



Scanned with CamScanner

ខែកញ្ញា ឆ្នាំ២០១៦ ស្ថិតនៅភូមិពូជ្រៃចាង ឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី និងដីទំហំ៧២០០ ម៉ែត្រការ៉េ ដែលមានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ១០០៣/១៦ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៦ ស្ថិតនៅភូមិពូជ្រៃចាង ឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ខ្លួនសុំប្រគល់ទៅឲ្យកូនឈ្មោះ [redacted] អ៊ីហ្វី ភេទស្រី អាយុ១១ឆ្នាំ និងឈ្មោះ [redacted] គិរីរម្យ ភេទប្រុស អាយុ៦ឆ្នាំ។ ចំពោះទ្រព្យសម្បត្តិរួមខាងលើ ដែលដើមចោទសុំឲ្យខ្លួនជាអ្នកគ្រប់គ្រងថែរក្សាជាបណ្តោះអាសន្ន រហូតកូនដល់វ័យនីតិភាពខ្លួនឯកភាព។ ចំពោះសិទ្ធិគ្រប់គ្រងអំណាចមេបាលើកូនឈ្មោះ [redacted] អ៊ីហ្វី ភេទស្រី អាយុ១១ឆ្នាំ និងឈ្មោះ [redacted] គិរីរម្យ ភេទប្រុស អាយុ៦ឆ្នាំ ខ្លួនស្របតាមការសម្រេចចិត្តរបស់កូនទាំងពីរ។

៣. អង្គហេតុគ្មានវិវាទ

៣.១ ដើមចោទបានរៀបអាពាហ៍ពិពាហ៍នៅអំឡុងឆ្នាំ២០០៦ ជាមួយចុងចម្លើយឈ្មោះ [redacted] ផុន្និ ប៉ុន្តែពុំមានចុះសំបុត្រអាពាហ៍ពិពាហ៍នោះទេ និងបានរួមរស់ជាមួយគ្នា រហូតដល់បច្ចុប្បន្នមានកូនចំនួន០២ នាក់ មានឈ្មោះ [redacted] អ៊ីហ្វី ភេទស្រី អាយុ១១ឆ្នាំ និងឈ្មោះ [redacted] គិរីរម្យ ភេទប្រុស អាយុ០៦ឆ្នាំ ព្រមទាំងមានទ្រព្យសម្បត្តិរួម៖ ដីទំហំ៣៣៩ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ១១០៥០២០២-០០៧២ ស្ថិតនៅភូមិពូជ្រៃចាង ឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ,ដីទំហំ១១៧៥២ ម៉ែត្រការ៉េ ដែលមានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ១០០២/១៦ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៦ ស្ថិតនៅភូមិពូជ្រៃចាង ឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី និងដីទំហំ៧២០០ ម៉ែត្រការ៉េ ដែលមានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ១០០៣/១៦ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៦ ស្ថិតនៅភូមិពូជ្រៃចាង ឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី។

៣.២ ដើមចោទ និងចុងចម្លើយសុខចិត្តប្រគល់ទ្រព្យសម្បត្តិអចលនវត្ថុទាំង០៣ កន្លែងខាងលើ ឲ្យទៅកូនឈ្មោះ [redacted] អ៊ីហ្វី ភេទស្រី អាយុ១១ឆ្នាំ និងឈ្មោះ [redacted] គិរីរម្យ ភេទប្រុស អាយុ០៦ឆ្នាំ ។

៣.៣ ចំពោះសិទ្ធិអំណាចមេបាលើកូនទាំងពីរ ដើមចោទ និងចុងចម្លើយគោរពតាមការសម្រេចចិត្តរបស់កូន ក្នុងការរស់នៅជាមួយដើមចោទ ឬចុងចម្លើយ។

## ការពិនិត្យភស្តុតាង

១.ការសាកសួរភាគី និងអ្នកពាក់ព័ន្ធ

-ដើមចោទ និងចុងចម្លើយបានព្រមព្រៀង តាមខ្លឹមសារនៃកិច្ចព្រមព្រៀងស្តីពីការលែងលះដោយស្ម័គ្រចិត្ត ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ។

-កូនឈ្មោះ [redacted] អ៊ីហ្វី ភេទស្រី អាយុ១១ឆ្នាំ និងឈ្មោះ [redacted] គិរីរម្យ ភេទប្រុស អាយុ០៦ឆ្នាំ សុខចិត្តរស់នៅជាមួយឪពុក ដែលជាចុងចម្លើយ។

១. ភស្តុតាងជាឯកសាររបស់គូរភាគី

-សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតលេខ៦៥ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ក្នុងសៀវភៅលេខ០១ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០។ល។



Scanned with CamScanner

-សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតលេខ៦៤ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ក្នុងសៀវភៅលេខ០១ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០។

-កិច្ចព្រមព្រៀងស្តីពីការលែងលះដោយស្ម័គ្រចិត្ត ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ១១០៤០២០២-០០៧២ ស្ថិតនៅភូមិពូជ្រៃចាង ឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី (ថតចម្លង)។

-ដីដែលមានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ១០០២/១៦ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៦ ស្ថិតនៅភូមិពូជ្រៃចាង ឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី (ថតចម្លង)។

- និងដីដែលមានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ១០០៣/១៦ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៦ ស្ថិតនៅភូមិពូជ្រៃចាង ឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី (ថតចម្លង)។

## សំអាងហេតុ

១. ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍នៅក្នុងឆ្នាំ២០០៦ ប៉ុន្តែពុំមានចុះសំបុត្រអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ដើម្បីបំពេញលក្ខខណ្ឌដែលមានចែងតាមបញ្ញត្តិមាត្រា៩៥៥ នៃក្រមរដ្ឋប្បវេណីទេ ដូច្នេះមិនចាត់ទុកថាដើមចោទ និងចុងចម្លើយជាប្តីប្រពន្ធស្របច្បាប់នោះទេ។ ចំពោះបណ្តឹងទាមទារលែងលះរបស់ដើមចោទមានលក្ខណៈផ្ទុយច្បាប់ដែលចំណុចនេះពុំអាចកែប្រែបាន ដូច្នេះគប្បីតុលាការលើកចោលបណ្តឹងនេះតាមបញ្ញត្តិមាត្រា៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២. ដោយសារតែដើមចោទ និងចុងចម្លើយមិនអាចចាត់ទុកជាប្តីប្រពន្ធស្របច្បាប់ ដូច្នេះភាគីដើមចោទ និងចុងចម្លើយមានសេរីភាពពេញលេញ ក្នុងការរៀបអាពាហ៍ពិពាហ៍ជាមួយបុរស ឬនារីណាដែលខ្លួនស្ម័គ្រចិត្ត ស្របតាមច្បាប់ ដោយពុំត្រូវបានជំទាស់ រារាំង ឬហាមឃាត់ពីសំណាក់ពីភាគីណាមួយឡើយ។

៣. ក្រោយរៀបអាពាហ៍ពិពាហ៍រួច ដើមចោទ និងចុងចម្លើយបានរួមរស់ជាមួយគ្នា ហើយបានបង្កើតកូនចំនួន០២នាក់ មានឈ្មោះ [redacted] ស៊ីហ្វី ភេទស្រី អាយុ១១ឆ្នាំ និងឈ្មោះ [redacted] គីរីរម្យ ភេទប្រុស អាយុ៦ឆ្នាំ។ ដើមចោទ និងចុងចម្លើយ បានឯកភាពគ្នា ដោយផ្តល់សិទ្ធិឱ្យកូនទាំងពីរជាអ្នកសម្រេចក្នុងការរស់នៅជាមួយដើមចោទ ឬចុងចម្លើយ។ តុលាការបានធ្វើការសាកសួរឈ្មោះ [redacted] ស៊ីហ្វី និងឈ្មោះ [redacted] គីរីរម្យ ហើយអ្នកទាំងពីរបានបញ្ជាក់ថា ពួកខ្លួនសុខចិត្តរស់នៅជាមួយចុងចម្លើយ។ ម្យ៉ាងទៀត បច្ចុប្បន្នភាគីចុងចម្លើយជាអ្នកគ្រប់គ្រងថែរក្សាកូនទាំងពីរ ដោយបានផ្គត់ផ្គង់ឱ្យកូនបានសិក្សានៅសាលាឯកជនផងដែរ។ ដូច្នេះការប្រគល់សិទ្ធិអំណាចមេបាលើកូន ឱ្យទៅភាគីចុងចម្លើយ គឺជាចម្រើសល្អបំផុតសម្រាប់ធានាបាននូវផលប្រយោជន៍អនីតិជន ហើយការប្រគល់នេះ គឺស្របទៅតាមឆន្ទៈរបស់អនីតិជនផងដែរ។ ប៉ុន្តែភាគីដើមចោទដែលមិនបានរស់នៅជាមួយកូន ដោយគ្មានសិទ្ធិអំណាចមេបានោះ មានសិទ្ធិចូលជួបប្រាស្រ័យទាក់ទងជាមួយកូនតាមច្បាប់ ស្របតាមមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី។

៤. ក្នុងអំឡុងនៃការរួមរស់ជាមួយគ្នា ភាគីដើមចោទ និងចុងចម្លើយ ទទួលបាននូវទ្រព្យជាអចលនវត្ថុចំនួន០៣កន្លែងមានដូចជា៖ ដីទំហំ៣៣៩ **ម៉ែត្រការ៉េ** ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ១១០៤០២០២-០០៧២ មានទីតាំងនៅភូមិពូជ្រៃចាង ឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី។ ដីទំហំ**១១.៧៥២ ម៉ែត្រការ៉េ** មានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ១០០២/១៦ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៦ មានទីតាំងនៅភូមិពូជ្រៃចាង ឃុំពូជ្រៃ ស្រុកពេជ្រាដា



Scanned with CamScanner

ខេត្តមណ្ឌលគិរី និងដីទំហំ៧.២០០ ម៉ែត្រការ៉េ មានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ១០០៣/១៦ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៦ មានទីតាំងនៅភូមិពូជ្រៃចាង ឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី។ ចំពោះទ្រព្យសម្បត្តិទាំងនេះ ភាគីដើមចោទ និងចុងចម្លើយ បានឯកភាពគ្នាប្រគល់ឲ្យកូនទាំងពីរ នៅពេលគ្រប់អាយុនីតិភាព (១៨ឆ្នាំ)។ ដូច្នេះគប្បីសម្រេចតាមការព្រមព្រៀងរបស់គូភាគី តាមមាត្រា៩៨០ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណី។

៥. ប្រាក់ប្រដាប់ក្តីគប្បីអនុវត្តតាមមាត្រា ៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្តីសម្រេចបញ្ចប់

១-លើកចោលបណ្តឹងលែងលះរបស់ដើមចោទឈ្មោះ **ថើប សុភា** ។

២-ឲ្យចុងចម្លើយឈ្មោះ [redacted] **ផុន្នី** មានសិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted] **អ៊ីហ្វី** ភេទស្រី អាយុ១១ឆ្នាំ និងឈ្មោះ [redacted] **គិរីរម្យ** ភេទប្រុស អាយុ៦ឆ្នាំ។ ប៉ុន្តែដើមចោទមានសិទ្ធិចូលជួបប្រាស្រ័យទាក់ទងជាមួយកូនទាំងពីរ តាមពេលវេលា និងទីកន្លែងសមរម្យ ហើយចុងចម្លើយត្រូវបង្កបរិយាកាស និងមធ្យោបាយងាយស្រួលដល់ដើមចោទ ។

៣-ទ្រព្យសម្បត្តិជាអចលនវត្ថុចំនួន០៣ កន្លែងមាន៖ ដីទំហំ៣៣៩ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ១១០៤០២០២-០០៧២ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៣ ស្ថិតនៅភូមិពូជ្រៃចាង ឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ,ដីទំហំ**១១៧៥២** ម៉ែត្រការ៉េ ដែលមានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ១០០២/១៦ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៦ ស្ថិតនៅភូមិពូជ្រៃចាង ឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី និងដីទំហំ**៧២០០** ម៉ែត្រការ៉េ ដែលមានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ១០០៣/១៦ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៦ ស្ថិតនៅភូមិពូជ្រៃចាង ឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ប្រគល់ឲ្យទៅកូនឈ្មោះ [redacted] **អ៊ីហ្វី** ភេទស្រី អាយុ១១ឆ្នាំ និងឈ្មោះ [redacted] **គិរីរម្យ** ភេទប្រុស អាយុ៦ឆ្នាំ តាមការព្រមព្រៀងរបស់ភាគី។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

ក្នុងករណីមានបណ្តឹងឧទ្ធរណ៍ត្រូវធ្វើឡើងក្នុងអំឡុងពេលដែលច្បាប់កំណត់។

ថ្ងៃអង្គារ២កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ពស ២៥៦៥

មណ្ឌលគិរី, ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០២១

**ចៅក្រម**

**ហត្ថលេខា និងត្រា៖** [redacted]

---

**បានឃើញ**

**ចៅក្រម**

[redacted]

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃអង្គារ២កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ពស២៥៦៥

មណ្ឌលគិរី, ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner